ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ៥៧/០២៣-០០១ សណន....

ថ្ងៃព្រហស្បតិ៍ ១១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣

# សារាចរណែនាំ
## ស្តីពី
## ការរៀបចំឥណទានឡើងវិញចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាប

ក្នុងគោលបំណងគាំទ្រកំណើនសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តទៅនេះហៅថា "គ្រឹះស្ថាន" រៀបចំឥណទានឡើងវិញចំពោះឥណទានដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍នៅខេត្តសៀមរាប ដើម្បីជួយសម្រាលបន្ទុកអតិថិជនដែលកំពុងប្រឈមនឹងការធ្លាក់ចុះនៃប្រាក់ចំណូលចម្បងពីវិស័យទេសចរណ៍ដែលធ្វើឱ្យមានការលំបាកក្នុងការទូទាត់សងឥណទានទៅគ្រឹះស្ថាន ដោយត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

- ឥណទានដែលទទួលបានលក្ខខណ្ឌអនុគ្រោះណាមួយដូចខាងក្រោម ត្រូវចាត់ទុកថា "ឥណទានរៀបចំឡើងវិញ"៖
  ១/- ការកាត់បន្ថយចំនួនប្រាក់ដើមឥណទាន ឬចំនួនដែលត្រូវសងនៅឥណប្រតិទាន
  ២/- ការបន្ថយអត្រាការប្រាក់ទាបជាងលក្ខខណ្ឌនៃកិច្ចសន្យាដើម
  ៣/-ការពន្យារពេលទូទាត់សងប្រាក់ដើម ឬការប្រាក់ ឬការធ្វើមូលធនកម្មការប្រាក់
  ៤/- ការពន្យារឥណប្រតិទាន
  ៥/- ការបន្ថែម និង/ឬ ការផ្លាស់ប្តូរអ្នករួមខ្ចី និង/ឬ អ្នកធានា ប្រសិនបើមាន
  ៦/- ការផ្លាស់ប្តូរពីឥណទានមានការទូទាត់សងតាមការបង់រំលស់ ទៅជាការទូទាត់ការប្រាក់ ហើយទូទាត់សងប្រាក់ដើមទាំងអស់នៅឥណប្រតិទាន (Bullet Loan)
  ៧/-ការលើកលែង ឬ បន្ថយទ្រព្យធានា
  ៨/- ការបន្ថយលក្ខខណ្ឌកិច្ចសន្យា និង/ឬ
  ៩/- ការផ្តល់រយៈពេលអនុគ្រោះដោយគ្មានការទូទាត់សង (Grace period) ដែលអាចមានរយៈពេលរហូតដល់ ៦ខែ គិតចាប់ពីថ្ងៃប្រសិទ្ធភាពនៃកិច្ចសន្យាថ្មី។
- គ្រឹះស្ថានត្រូវរៀបចំឥណទានឡើងវិញចំពោះអតិថិជន ដែលស្ថានភាពអាជីវកម្ម និង/ឬ ស្ថានភាពហិរញ្ញវត្ថុនៅតែមានចីរភាព ហើយគ្រឹះស្ថានរំពឹងថាអតិថិជនជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុ និងការទូទាត់សងតែក្នុងរយៈពេលបណ្តោះអាសន្នប៉ុណ្ណោះហើយអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចទូទាត់សងនាថ្ងៃខាងមុខ តាមលក្ខខណ្ឌថ្មីនៃកិច្ចសន្យា។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- គ្រឹះស្ថានអាចរៀបចំឥណទានឡើងវិញ បានចំនួន ០២ដង គិតចាប់ពីថ្ងៃប្រសិទ្ធភាពនៃសារាចរណែនាំនេះ រហូតដល់ដំណាច់ខែធ្នូ ឆ្នាំ២០២៤។ គ្រឹះស្ថានអាចរក្សាចំណាត់ថ្នាក់ឥណទានល្អបំផុតត្រឹមចំណាត់ថ្នាក់មុនពេលរៀបចំឥណទានឡើងវិញ និងមិនចាំបាច់ធ្វើសំវិធានធនបន្ថែមឡើយ។
- បន្ទាប់ពីរៀបចំឥណទានឡើងវិញ ប្រសិនបើគ្រឹះស្ថានវាយតម្លៃឃើញថាស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុនិងការខកខានទូទាត់សងរបស់អតិថិជន មិនមែនជាស្ថានភាពបណ្ដោះអាសន្ន គ្រឹះស្ថានត្រូវទម្លាក់ចំណាត់ថ្នាក់ឥណទាននិងត្រូវធ្វើសំវិធានធនបន្ថែមចំពោះឥណទានរៀបចំឡើងវិញនោះភ្លាម។
- គ្រឹះស្ថានអាចអនុវត្តការដំឡើងចំណាត់ថ្នាក់ឥណទាន ដោយផ្អែកលើការវាយតម្លៃលទ្ធភាពទូទាត់សងរបស់អតិថិជនរយៈពេល ៦ខែ (៣ខែសម្រាប់ឥណទានរយៈពេលខ្លី) បន្ទាប់ពីរយៈពេលអនុគ្រោះចុងក្រោយ (ដំណាច់ខែធ្នូ ឆ្នាំ២០២៤) ស្របតាមប្រកាសស្ដីពីចំណាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនលើអ៊ីមតែរមិន និង
- គ្រឹះស្ថានត្រូវរាយការណ៍អំពីឥណទានរៀបចំឡើងវិញនេះ ជាប្រចាំខែ តាមទម្រង់របាយការណ៍ដូចមានក្នុងឧបសម្ព័ន្ធ។

គ្រឹះស្ថានត្រូវមានតម្លាភាពក្នុងការផ្ដល់ព័ត៌មានត្រឹមត្រូវគ្រប់ជ្រុងជ្រោយ និងត្រូវពន្យល់អតិថិជនឱ្យបានច្បាស់លាស់អំពីលក្ខខណ្ឌនៃការរៀបចំឥណទានឡើងវិញ ដើម្បីឱ្យអតិថិជនមានមូលដ្ឋានក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។

សារាចរណែនាំនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសាភិបាល**

ជា_សិរី

**កន្លែងទទួល៖**

- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋានត្រួតពិនិត្យ
- អគ្គនាយកដ្ឋានបច្ចេកទេស
- អគ្គបេឡា
- អគ្គាធិការដ្ឋាន
- គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ